# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥៥ ស្ដីពី ការបញ្ចប់តំណែងទីប្រឹក្សា ជំនួយការព្រមទាំងនាយក នាយករង និងជំនួយការខុទ្ទកាល័យ សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា | ៥៧៧៩ |
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥៦ ស្ដីពី ការតែងតាំងជាទីប្រឹក្សា និងនាយិកាខុទ្ទកាល័យ ឯកឧត្ដម **នៃ ប៉េណា** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី ៣ | ៥៧៨២ |
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥៧ ស្ដីពី ការតែងតាំងលោកជំទាវ **ឆិន ស៊ុយៀក** ជាទីប្រឹក្សា ឯកឧត្ដម **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើរដ្ឋលេខាធិការ | ៥៧៨៤ |
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ លោកជំទាវ លោកស្រី និងអស់លោក ចំនួន ២០ រូប | ៥៧៨៥ |
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អស់លោក និងកងកម្លាំងប្រដាប់អាវុធ ចំនួន ២២ រូប | ៥៧៨៦ |
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី និងព្រះសង្ឃ ចំនួន ៣៥ រូប/អង្គ | ៥៧៨៨ |
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦១ ស្ដីពី ការតម្លើងឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃចំនួន ២ រូប | ៥៧៩០ |
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦២ ស្ដីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ចំនួន ១០ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្ដីការគណៈរដ្ឋមន្ត្រី | ៥៧៩១ |
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦៣ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្ដម លោកជំទាវ ចំនួន ៨ រូប | ៥៧៩៣ |
| ២២-៦-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសសុវត្ថារា តាមលំដាប់ថ្នាក់ ចំពោះ អស់លោក លោកស្រី និងព្រះសង្ឃ ចំនួន ២៣ រូប/អង្គ | ៥៧៩៤ |

២២-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍ ចំពោះ លោក H.E.Jean François Cautain ៥៧៩៥

២២-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ អស់លោក ចំនួន ៣ រូប ៥៧៩៦

២២-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្ដម អស់លោក និងលោកស្រី ចំនួន ១៩ រូប ៥៧៩៧

២៥-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦៨ ស្ដីពី ការតែងតាំងលោកជំទាវ **ស៊ិន ស៊ីមុន្នី** ជាទីប្រឹក្សាសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មាន ឋានៈស្មើ អគ្គនាយក ដោយមិនទទួលយកប្រាក់បៀវត្ស ៥៧៩៨

២៥-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៦៩ ស្ដីពី ការតែងតាំងឥស្សរជន ចំនួន ០៥ រូប ជា ទីប្រឹក្សាក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ៥៧៩៩

២៥-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៧០ ស្ដីពី ការតែងតាំងឯកឧត្ដម **ម៉ាន់ សារ៉ាន់** ជា ទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ៥៨០០

២៥-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៧១ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ចឹង លីងឡី** (ZENG LINGLEI) ជនជាតិចិន សញ្ជាតិចិន ៥៨០១


## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


០៩-៧-២០១៥ -អនុក្រឹត្យលេខ ៨៩ អនក្រ.បក ស្ដីពី ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ ក្រសួង បរិស្ថាន ៥៨០២

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧២៣ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៨២៦

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧២៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨២៧

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧២៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៨២៨

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧២៦ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៨៣០

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧២៧ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨៣២

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧២៨ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៥៨៣៣

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧២៩ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៨៣៥

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧៣០ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៨៣៧

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧៣១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៨៣៨

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧៣២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៨៤០

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧៣៣ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ៥៨៤២

០៧-៧-២០១៥ -អនុក្រឹត្យលេខ ៧៣៤ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៥៨៤៣

## ២-សេចក្តីសម្រេច

០៩-៧-២០១៥ -សេចក្តីសម្រេចលេខ ៥២ សសរ ស្តីពី ការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម ៥៨៤៤

០៩-៧-២០១៥ -សេចក្តីសម្រេចលេខ ៥៣ សសរ ស្តីពី ការតែងតាំងសមាសភាពក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ៥៨៤៨

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៩-៦-២០១៥ -ប្រកាសលេខ ៦៦១ សហវ.ប្រក ស្តីពី ការបង្កើតអង្គភាពទទួលបន្ទុកគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ៥៨៥០

០៩-៦-២០១៥ -ប្រកាសលេខ ៦៦២ សហវ.ប្រក ស្តីពី ការតែងតាំងក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៥៨៥៣

០៩-៦-២០១៥ -ប្រកាសលេខ ៦៦៣ សហវ.ប្រក ស្តីពី ការបង្កើតគណៈកម្មការសម្របសម្រួលគម្រោងសាងសង់ស្ពាន និងផ្លូវល្បឿនលឿនក្រោមទម្រង់វិនិយោគ សាងសង់-ប្រតិបត្តិការ-ផ្ទេរ (BOT) របស់វិទ្យាស្ថានរចនាសិក្សាស្រាវជ្រាវគម្រោងប្លង់គមនាគមន៍ខេត្តហឺណាន សាធារណរដ្ឋប្រជាមានិតចិន ៥៨៥៥

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

៣០-៤-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ១៧៣ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុនអេធិច អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៥៨៥៨

៣០-៤-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ១៧៤ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុនបាយ័ន ហ្គាមេន ហ្វាកធើរី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៥៨៦១

៣០-៤-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ១៧៥ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុនខេមបូ ហ៊ែនសាំ អិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៥៨៦៤

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រា ទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា បានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់លទ្ធផល នៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំវិសាមញ្ញ នីតិកាលទី ៣ នៃព្រឹទ្ធសភា នាថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៥ ស្តីពីការជ្រើសតាំងប្រធាន និងអនុប្រធានទី១ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានបញ្ចប់តំណែងទីប្រឹក្សា ជំនួយការ ព្រមទាំងនាយក នាយករង និងជំនួយការខុទ្ទកាល័យ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា ដែលបានទទួលការតែងតាំងមុនថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ។

**មាត្រា២ :** ត្រូវបានបញ្ចប់តំណែងទីប្រឹក្សា ជំនួយការ ព្រមទាំងនាយក នាយករងខុទ្ទកាល័យ **ឯកឧត្តម សាយ ឈុំ** អនុប្រធានទី១ព្រឹទ្ធសភា ដែលបានទទួលការតែងតាំង មុនថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ ។

**មាត្រា៣ :** តែងតាំងជាទីប្រឹក្សា ព្រមទាំងនាយក និងនាយករងខុទ្ទកាល័យ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ម៉ម សារិន** | ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យ មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

២- ឯកឧត្តម **ចំម ឡេងយ៉ាធី** ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ
មានឋានៈស្មើ **រដ្ឋមន្ត្រី**

៣- ឯកឧត្តម **ហង់ ថុណ** ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ
មានឋានៈស្មើ **រដ្ឋមន្ត្រី**

៤- លោកជំទាវ **សាយ ចាន់ណាក់** ជាទីប្រឹក្សា និងជានាយិការងខុទ្ទកាល័យ
មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៥- ឯកឧត្តម **ឈួរ លាងហួត** ជាទីប្រឹក្សា មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី**

៦- ឯកឧត្តម **សោម សឿន** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**
បន្ថែមលើមុខងារបច្ចុប្បន្ន

៧- ឯកឧត្តម **តាក ស៊ុនអ៊ី** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**

៨- ឯកឧត្តម **យឹម ណាង** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**
បន្ថែមលើមុខងារបច្ចុប្បន្ន

៩- ឯកឧត្តម **បៃនសុន សម័យ** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**

១០- លោកជំទាវ **ព្រំ ស៊ិត** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**

១១- ឯកឧត្តម **រស់ ស្រេង** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**

១២- ឯកឧត្តម **រុង ផ្កាម៉ៃសន** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**

១៣- ឯកឧត្តម **នុច ថន** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**

១៤- ឯកឧត្តម **ឡេង ប៊ុនពេង** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**
បន្ថែមលើមុខងារបច្ចុប្បន្ន

១៥- ឯកឧត្តម **ខ្វង សុជាតិ** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**

១៦- ឯកឧត្តម **សត្យា វុធ** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**

១៧- ឯកឧត្តម **ប៊ូ យឿង** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**

១៨- ឯកឧត្តម **ហ៊ុក ស៊ីវ** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**

១៩- លោកជំទាវ **សំ នារី** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**

២០- ឯកឧត្តម **ឡុង ពៅប្រាជ្ញា** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**

២១- ឯកឧត្តម **កែវ ធី** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**

២២- ឯកឧត្តម **គីម យិន** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ២៣- | លោកជំទាវ **មៀច សុផារី** | ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ២៤- | ឯកឧត្តម **ស៊ឹម ហង្ស** | ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ២៥- | ឯកឧត្តម **អ៊ិក គឹមហាន** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ២៦- | ឯកឧត្តម **ម៉ឹង សុវណ្ណា** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ២៧- | ឯកឧត្តម **លុយ ឡាំ** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ២៨- | ឯកឧត្តម **ជា ហ្គារ៉ូដា** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ២៩- | ឯកឧត្តម **ឡូយ ឫទ្ធី** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ៣០- | ឯកឧត្តម **ឯល ប៊ុនណា** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ៣១- | ឯកឧត្តម **ឯម សុនី** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣២- | ឯកឧត្តម **សុត រស្មី** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣៣- | ឯកឧត្តម **ចាន់ សុវណ្ណឌី** | ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ៣៤- | ឯកឧត្តម **វណ្ណ សុខខេង** | ជាទីប្រឹក្សា មានឋានៈស្មើ **អគ្គនាយក** |
| ៣៥- | ឯកឧត្តម **សុខ សាផុន** | ជាទីប្រឹក្សា មានឋានៈស្មើ **អគ្គនាយក** |
| ៣៦- | ឯកឧត្តម **ទេព មាន** | ជាទីប្រឹក្សា មានឋានៈស្មើ **អគ្គនាយក** |
| ៣៧- | ឯកឧត្តម **ពូល នៅ** | ជាទីប្រឹក្សា មានឋានៈស្មើ **អគ្គនាយក** |
| ៣៨- | ឯកឧត្តម **ជា សុវណ្ណា** | ជាទីប្រឹក្សា មានឋានៈស្មើ **អគ្គនាយក** |

**មាត្រា៤ :** **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៥ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១៥០៦.៦៦១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៦៧៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៥៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រា ទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា បានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់លទ្ធផល នៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំវិសាមញ្ញ នីតិកាលទី ៣ នៃព្រឹទ្ធសភា នាថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៥ ស្តីពីការជ្រើសតាំងប្រធាន និងអនុប្រធានទី១ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងជាទីប្រឹក្សា និងនាយិកាខុទ្ទកាល័យ **ឯកឧត្តម ង៉ែ ប៉េណា អនុប្រធានទី១ ព្រឹទ្ធសភា** នីតិកាលទី៣ :

១- ឯកឧត្តម **ម៉ី ភី** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋមន្ត្រី**

២- ឯកឧត្តម **គុយ សាវុធ** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៣- ឯកឧត្តម **ខុន ណារិទ្ធ** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤- ឯកឧត្តម ភា ហួយ ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**

៥- ឯកឧត្តម នៃ គង់ ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៦- ឯកឧត្តម ប៊ុន សារ៉េត ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៧- លោកជំទាវ នៃ តុលា ជានាយិកាខុទ្ទកាល័យ ឋានៈ **អគ្គនាយក**

**មាត្រា២ :** **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**

**នរោត្តម សីហមុនី**

នស/រកត.០៦១៥.៦៦២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៧២ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៥៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់ឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រា ទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា បានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់លទ្ធផល នៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំវិសាមញ្ញ នីតិកាលទី ៣ នៃព្រឹទ្ធសភា នាថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៥ ស្តីពីការជ្រើសតាំងប្រធាន និងអនុប្រធានទី១ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តែងតាំង**លោកជំទាវ និន ស៊ុយៀក** ជាទីប្រឹក្សា**ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ :** **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៥០៦.៦៦៣

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥

លេខ: ៦៧៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៥៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ជាតូបការ :
លោកជំទាវ ម៉ែន មាណវី

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :
១-លោកជំទាវ ស៊ីន សុម៉ាលី
២-លោក កុយ រតនៈបណ្ឌិត
៣-លោក ខែត រដ្ឋា
៤-លោក ម៉ែន អាន

គ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ :
Mr. Seong-hyeog Yim

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា:
១-លោកស្រី ហង់ សុជីវី
២-លោក បូរី ចន្ទសានិត្យ
៣-លោក ថាន់ ធុទ្ធីរ៉ា
៤-លោក ហ៊ុយ សោភ័ណជារិទ្ធ
៥-លោក ចាន់ ធន់
៦-លោក អ៊ុក ចាន់តារ៉ា
៧-លោក សៅ ប្រេមរ៉ារក្ស
៨-លោក សុខ សំអន

ង-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា:
១-Mr. Jong Bok,Lee
២-Mr. Doo Hwa,Lee
៣-Mr. Sang Cheol,Park

ច-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :
លោក ប៉ាល់ ឆន

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :
លោក ជា ហុង

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ:
លោក ចន្ទ ច័ន្ទសុភ័ក្ត្រ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

១៣. ១៥០៦. ៦៥៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥

លេខ: ៦៧៧ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**ដូច**

**ក.** គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១-លោកឧត្តមសេនីយ៍ត្រី **ឡុង គីមរៀន** អត្តលេខ ០៥៩៣
២-លោកវរសេនីយ៍ឯក **ជា សុភាព** អត្តលេខ ០១៤៧៣
៣-លោកវរសេនីយ៍ឯក **សន សារឿន** អត្តលេខ ០១០៦៩
៤-លោកវរសេនីយ៍ឯក **ចន្ទ្រនៈ មង្គល** អត្តលេខ ៥៧៨៧២
៥-លោកវរសេនីយ៍ទោ **មូល បូណា** អត្តលេខ ០៧២៦៨
៦-លោកវរសេនីយ៍ទោ **នាង ណាន** អត្តលេខ ០៧២០៤
៧-លោកវរសេនីយ៍ទោ **សេង ឫទ្ធី** អត្តលេខ ០២២១៦
៨-លោកវរសេនីយ៍ទោ **ទេព ចន្ថា** អត្តលេខ ០៥៤១៤
៩-លោកវរសេនីយ៍ត្រី **ម៉ែន សុផល** អត្តលេខ ០៧២១០
១០-លោក **មួន ឌីណា**
១១-លោក **ហ៊ុយ ធីតា**
១២-លោក **សែ បូរិន**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**ខ.** គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

លោកសាស្ត្រាចារ្យ **ពៅ ពិសិដ្ឋ**

**គ.** គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

លោកឧត្តមសេនីយ៍ត្រី **ខ៊ែត ឆា** អត្តលេខ ០៩៨៩

**ឃ.** គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់**មហាសេរីវឌ្ឍន៍** :

១-លោកឧត្តមសេនីយ៍ត្រី **គង់ មនោ** អត្តលេខ ១៥៨៣១

២-លោក **សេង សុផល**

៣-លោក **ឯក សារិទ្ធ**

៤-លោក **អ៊ុយ សាគុណ**

៥-លោក **ឡេង អូន**

**ង.** គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសមៈ នារីរត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោកឧត្តមសេនីយ៍ត្រី **ហោក ជិនលីន** អត្តលេខ ០៥៩៤

២-លោក **មុនី សីហា**

**ច.** គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** :

លោកវរសេនីយ៍ទោ **អ៊ឹម៉ាសា យូណា** អត្តលេខ ៦២៨០២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត/០៦១៥/៦៦៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៧៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ មិថុ ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៦០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**ដូច**

**ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម **ហ៊ីន សយ** ២- ឯកឧត្តម **ម៉ាត់ ម៉ូត**
៣- ឯកឧត្តម **នង់ យ៉ោ** ៤- លោក **ពៅ ស៊ីថា**
៥- លោក **អ៊ុត គីឡា** ៦- លោក **មាន់ អ៊ានលី**

**ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- លោក **ម៉ម ឈឿម**

**គ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ព្រះតេជគុណ **យឹម ទូច**

**ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- ឯកឧត្តម **ហ៊ី ណាត** ២- ឯកឧត្តម **ស៊ីច រុន**
៣- ឯកឧត្តម **អ៊ីង លាងហ៊្សួ** ៤- លោក **អម សុភា**
៥- លោក **អ៊ុន សុផល** ៦- លោក **ហ៊ួល ច័ន្ទថូ**
៧- លោកស្រី **នួន ចាន់នី** ៨- លោក **កែវ សឿនសោភ័ណ**
៩- លោក **ឌីម ឆន**

**ង- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

១- ឯកឧត្តម **សោម គិរុណ** ២- លោក **ឱត្យ ណាន**
៣- លោក **យឹម លទ្ធី** ៤- លោក **ពៅ សារឿន**

**ច- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១- ឯកឧត្តម **ឡុង ឈុនឡៃ** ២- ឯកឧត្តម **សួន សាត**

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

៣- លោក អ៊ុំ ស៊ីថា                    ៤- លោក ហៃ មនោរម្យ

៥- លោក តាំ សារឿន

**ង- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ ធិបឌិន្ទ :**

១- លោកស្រី អ៊ឹម គួយអ៊ឹម

**ជ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១- ឯកឧត្តម គួយ ចន្ថា                    ២- លោកស្រី ប៉ុល សៅធី

**ឈ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ សេនា :**

១- លោក ស្វាយ ខិត                    ២- លោក ប្រាក់ សាងហួរ

**ញ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១- លោកជំទាវ គួច ណារី                    ២- លោកស្រី ឆួន ឈុយអេង

៣- លោក អ៊ុត រស់                    ៤- លោក សំ សិទ្ធី

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត/០៦១៥/៦៦៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៧១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៦១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ឯក **សុខ សំណាង** អត្តលេខ ០២១២១

២- លោកវរសេនីយ៍ឯក **ជា ផេង** អត្តលេខ ០៤៧៧៤ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពណ. ១៥០៦. ៦៦៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥

លេខ: ៦៦៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ចំនួន ១០ រូប ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ តទៅ ÷

| | | | |
|---|---|---|---|
| ១. លោក | **លី គឹមឆាយ** | អនុមន្ត្រី | ថ្នាក់លេខ ៣ |
| ២. លោក | **ឡាំ សំណាង** | អនុមន្ត្រី | ថ្នាក់លេខ ៣ |
| ៣. លោក | **ជឹម ត័ក្រា** | អនុមន្ត្រី | ថ្នាក់លេខ ៤ |

| | | | |
|---|---|---|---|
| ៤. លោក | **សួន សាខ៉ាតឌី** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ៥. លោក | **ជុយ គីមឡុង** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ៦. លោក | **ឡុង សុខលេង** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ៧. លោក | **ឡាច ចាសនា** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ៨. លោកស្រី | **សួន ស៊ីណុន** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ៩. លោកស្រី | **សួន ស៊ីណែត** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ១០. លោកស្រី | **ថាច់ ដាវីចារី** | អនុមន្ត្រី | ថ្នាក់លេខ ៤ ។ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.១៥០៦-៦៦៨

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៧២.ស.ណ

**សំណៅដែលមានអង្គេដាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ២៥.ខែ មិថុនា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៦១៥/៦៦៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

**ក-គ្រឿងឥស្សរិយយស ជាតូបការ :**
លោកជំទាវ **តឿង សគុណា**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**
១-ឯកឧត្តម **គង់ កន្ថារ៉ា**
២-ឯកឧត្តម **អ៊ុន ធីម**
៣-ឯកឧត្តម **ស្រី សួន**
៤-លោកជំទាវ **នេត្រ ភូម៉ារី**
៥-ឯកឧត្តម **ឆៀង វណ្ណដារ៉ុង**

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**
ឯកឧត្តម **ហ៊ឺ ធីរៈ**

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**
លោកជំទាវ **នឹង ស៊ីមន**

១៣៧.១៥០៦.៦៦៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៧៧ ស.ណ
**សំណៅដែលមានគម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ព្រះតេជគុណ **សុខ សុភាព**
២-លោក **ជា ថុន**
៣-លោក **សំបូរ ផុ**
៤-លោក **ឡៀម ជុំឡុង**
៥-លោក **អ៊ុច កុសល**
៦-លោក **អ៊ុក ជាវ៉ាន់ឌី**
៧-លោក **គីម ទាសនា**
៨-លោក **ពុំ ចាន់**
៩-លោក **អ៊ុកវង្ស ឡុងទី**
១០-លោក **អេង គីមហៃ**
១១-លោក **គីម សុផាត**
១២-លោក **វ៉េន ហុក**

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១-លោក **ទង់ រដ្ឋា**
២-លោក **ដួង ជីវ័ន្ត**
៣-លោក **ម៉ៅ សំអឿន**
៤-លោក **ឈួយ វណ្ណៈ**
៥-លោក **ស៊ុំ សំណាង**
៦-លោក **វ៉ាន់ ថុល**
៧-លោក **ទៀង សុម៉ាន់**
៨-លោក **រស់ វិសិទ្ធិ**
៩-លោកស្រី **ហូ ដានី**
១០-លោក **ពៅ ដាលីនណា**
១១-លោក **សួន ចាន់ឌី**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

១៣៧.១៥០៦.៦៧០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៧៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

នស/រកត/០៦១៥/៦៦៥

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ចំពោះ

**H.E. Jean François Cautain**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥០៦. ៦៧១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៧៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៦៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស **ជាតូបការ** :

១-លោក **ថម គិមសុន**

២-លោក **ព្រួង សំណាង**

៣-លោក **លួង ចាន់ហ៊ុយ**

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

៣៧.១៥០៦.៦៧៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: [illegible].ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម ជា សែ
២-ឯកឧត្តម សូ វិសុទ្ធី
៣-ឯកឧត្តម ស៊ឹម សួង
៤-ឯកឧត្តម គង់ សូលីដា
៥-លោក សុខ គុងហាប់

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១-ឯកឧត្តម ណេប សាមុត
២-ឯកឧត្តម សុខ សច្ចារ
៣-លោក ផ្លុង ធឿន

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា:**

១-លោក ម៉ម វាសនា
២-លោក ហេង សុខចំរើន
៣-លោក ជុក សុខុម

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្សឫទ្ធិ:**

១-លោក នឹម សុវណ្ណា
២-លោក ទួន សេដា
៣-លោក នឹង មុន្នី
៤-លោក ស្រ៊ន សុវណ្ណារ៉ា
៥-លោក សៀង នាគ
៦-លោកស្រី ចាយ សុវណ្ណនី
៧-លោក សេង ខា
៨-លោក ណែម ស៊ីវឡូនា

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

៣៧៧. ១៥០៦. ៦៧៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៩០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៦៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង លោកជំទាវ **ស៊ិន ស៊ីមុនី** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ដោយមិនទទួលយកប្រាក់បៀវត្ស ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១៥០៦. ៦៧៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៤៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៦៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឥស្សរជនចំនួន ០៥រូប ជាទីប្រឹក្សាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (ក.ក.ជ)÷

១. ឯកឧត្តម **ទីង យឹមហ៊ាង** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២. ឯកឧត្តម **កេតុ វណ្ណសិទ្ធី** មានឋានៈស្មើ អនុរដ្ឋលេខាធិការ
៣. ឯកឧត្តម **សុខ ចាន់តន្ត្រី** មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បៀវត្សរ៍
៤. ឯកឧត្តម **ហុង គីមហ៊ង** មានឋានៈស្មើ អគ្គនាយក ដោយមិនទទួលប្រាក់បៀវត្សរ៍
៥. ឯកឧត្តម **ខៀវ សុខា** មានឋានៈស្មើ អគ្គនាយក

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរជ.១៥០៦.៦៧៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៧៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ម៉ាន់ សារ៉ាន់** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១៥០៦.៦៧៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ:៦៤៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ចឹង លីងឡី** (ZENG LINGLEI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៣ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩ល.១៥០៦.៦៧៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៦៨៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៩...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ ក្រសួងបរិស្ថាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់នូវឯកសណ្ឋាន សញ្ញាសក្តិ មួក និងសញ្ញាសម្គាល់ ក្រសួងបរិស្ថាន សម្រាប់ប្រើប្រាស់បំពេញការងារនៅអង្គភាព និងចុះអនុវត្តច្បាប់ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាពសម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនគ្រប់រូបនិងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ឯកសណ្ឋាន សញ្ញាសក្តិ និងមួក

### ផ្នែកទី១

### ឯកសណ្ឋាន

**មាត្រា២.-**

មន្ត្រីអគ្គនាយកដ្ឋានគាំពារបរិស្ថាន និងអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ត្រូវប្រើប្រាស់ឯកសណ្ឋានក្នុងពេលបំពេញការងារនៅតាមអង្គភាពនិងបេសកកម្ម។

**មាត្រា៣.-**

ឯកសណ្ឋានរបស់មន្ត្រីអគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថានមានដូចខាងក្រោម៖

ក. ឯកសណ្ឋានពេលបំពេញការងារតាមបណ្តាអង្គភាព

ក.១- ឯកសណ្ឋានបុរស

- អាវដៃខ្លីក្រណាត់កាគីលាតពណ៌ស កបើក ជើងអាវត្រង់ ផែកចំហៀង ប៉ូលស្មា ហោប៉ៅពីរថ្មេរឧប មានស្ព័រកណ្តាល គម្របរាងចំណិតធ្នូបិទដោយឡេវ ខ្នងតស្មា លើដៃអាវខាងស្តាំមានបិទសញ្ញាសម្គាល់ក្រសួងបរិស្ថាន និងសញ្ញាសម្គាល់អង្គភាពនៅខាងឆ្វេង លើប៉ូលស្មាមានសញ្ញាសក្តិ និងលើហោប៉ៅផ្នែកខាងស្តាំមានបិទផ្លាកឈ្មោះនិងខាងក្រោមផ្លាកឈ្មោះមានពាក់សញ្ញាឡូហ្គោបរិស្ថាន
- ខោជើងវែងក្រណាត់កាគីលាតពណ៌កាគី ចង្កេះលាត ភ្លីមួយ ហោប៉ៅចំនួនបួនគឺហោប៉ៅចំហៀងមុខពីររាងបញ្ឆិត ហោប៉ៅក្រោយពីរបិទដោយឡេវ ថ្មេរសម្រុងធម្មតា ចុងជើងខោដេរ និងមានខ្សែដាក់ខ្សែក្រវ៉ាត់
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រម ទំហំក្បាលខ្សែក្រវ៉ាត់មានទទឹង ៣៨ម.ម. បណ្តោយ ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងបរិស្ថាននៅចំកណ្តាល
- ស្បែកជើងឃ្លុប មានកែង ពណ៌ខ្មៅ កខ្លី ចងខ្សែ។

ក.២- ឯកសណ្ឋានស្ត្រី

- អាវដៃខ្លីក្រណាត់កាគីលាតពណ៌ស កបើក ជើងអាវត្រង់ ផែកចំហៀង ប៉ូលស្មា ហោប៉ៅពីរថ្នេរឧប មានស្ល័រកណ្តាល គម្របរាងចំណិតធ្នូបិទដោយឡេវ ខ្ទង់តស្មា លើដៃអាវខាងស្តាំបិទសញ្ញាសម្គាល់ក្រសួងបរិស្ថាន និងសញ្ញាសម្គាល់អង្គភាពនៅខាងឆ្វេង លើប៉ូលស្មាមានសញ្ញាសក្តិ លើហោប៉ៅផ្នែកខាងស្តាំមានបិទផ្លាកឈ្មោះ និងខាងក្រោមផ្លាកឈ្មោះមានពាក់សញ្ញាឡូហ្គោបរិស្ថាន
- សំពត់ខ្លីសម្រុងក្រោមជង្គង់ ក្រណាត់កាគីលាតពណ៌កាគី ចង្កេះលាតបិទដោយឡេវទម្លក់មួយនៅចំលើក្បាលរូតផ្នែកខាងក្រោយ ផែកក្រោមផ្នែកខាងក្រោយប្រវែងមួយភាគបីនៃសម្រុងសំពត់ និងមានខ្សែដាក់ខ្សែក្រវ៉ាត់
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រម ទំហំក្បាលខ្សែក្រវ៉ាត់មានទទឹង៣៨ម.ម. និងបណ្តោយ ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួង បរិស្ថាននៅចំកណ្តាល
- ស្បែកជើងឃ្លុបមុខឃ្លុបក្រោយ មានកែង ពណ៌ខ្មៅ។

ឯកសណ្ឋានពេលបំពេញការងារតាមបណ្តាអង្គភាពរបស់មន្ត្រី អគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន មានភ្ជាប់ជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

ខ. ឯកសណ្ឋានបំពេញបេសកកម្មតាមទីវាល

- អាវយឺតដៃខ្លី ក្រណាត់លាតពណ៌បៃតងខ្ចី កបើកឡេវពីរ រឹបចុងដៃ សម្រុងត្រង់ និងលើដៃអាវខាងស្តាំមានសញ្ញាសម្គាល់ក្រសួងបរិស្ថាន និងខាងឆ្វេងមានសញ្ញាសម្គាល់អង្គភាព នៅផ្នែកខាងមុខស្តាំមានផ្លាកឈ្មោះ និងខាងឆ្វេងមានផ្លាកសញ្ញាទង់ជាតិ
- ខោជើងវែងក្រណាត់លាតពណ៌កាគី ចង្កេះលាត ភ្លីមួយ ដាក់រូត មានដាក់កៅស៊ូសងខាងចំហៀងចង្កេះ ប៉ានគូទ ប៉ានជង្គង់ ហោប៉ៅប្រាំបីគឺហោប៉ៅចំហៀងពីរដេរបញ្ឆិត ហោប៉ៅក្រោយពីរសងខាងដេរបញ្ឆិតបិទដោយស្កត់ប៉ាន ហោប៉ៅប៉ានចំហៀងលើជង្គង់សងខាងមានគម្របជីបភ្លីត្រង់ថ្នេរឧបបិទដោយស្កុតប៉ាន និងហោប៉ៅស្បោងខ្នាតតូចលើភ្លៅខាងឆ្វេង និងហោប៉ៅបង្កប់ខ្នាតតូចលើភ្លៅខាងស្តាំ សម្រុងខាងក្រៅថ្នេរឧប សម្រុងខាងក្នុងថ្នេរធម្មតា ចុងជើងដេរ និងមានខ្សែដាក់ខ្សែក្រវ៉ាត់
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រម ទំហំទទឹង៣៨ម.ម. និងបណ្តោយ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងបរិស្ថាននៅចំកណ្តាល
- ស្បែកជើងឃ្លុប កវែង ពណ៌កាគី ចងខ្សែ។

ឯកសណ្ឋានបំពេញបេសកកម្មតាមទីវាលរបស់មន្ត្រី អគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន មានភ្ជាប់ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៤.-**

ឯកសណ្ឋានរបស់មន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន មានដូចខាងក្រោម៖

ក. ឯកសណ្ឋានបំពេញការងារតាមបណ្តាអង្គភាព

ក.១- ឯកសណ្ឋានបុរស

- អាវដៃខ្លីក្រណាត់កាគីលាតពណ៌ពងមាន់ កបើក ជើងអាវត្រង់ ផែកចំហៀង ប៉ូលស្មា ហោប៉ៅពីរថ្មេរឧប មានស្ល៉ករកណ្តាល គម្របរាងចំណិតធ្នូបិទដោយឡេវ ខ្ទង់តស្មា លើដៃអាវខាងស្តាំមានសញ្ញាសម្គាល់ក្រសួងបរិស្ថាន និងនៅខាងឆ្វេងមានសញ្ញាសម្គាល់អង្គភាព លើប៉ូលស្មាមានសញ្ញាសក្តិ និងលើហោប៉ៅផ្នែកខាងស្តាំមានបិទផ្លាកឈ្មោះ និងខាងក្រោមផ្លាកឈ្មោះមានពាក់សញ្ញាឡូហ្គោបរិស្ថាន
- ខោជើងវែងក្រណាត់កាគីលាតពណ៌សំបកឪឡឹក ចង្កេះលាត ភ្លីមួយ ហោប៉ៅចំនួនបួនគឺហោប៉ៅចំហៀងមុខពីររាងបញ្ឆិត ហោប៉ៅក្រោយពីរបិទដោយឡេវ ថ្មេរសម្រុងធម្មតា ចុងជើងខោដេរ និងមានខ្សែដាក់ខ្សែក្រវ៉ាត់
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រម ទំហំទទឹង៣៨ម.ម.និងបណ្តោយ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងបរិស្ថាននៅចំកណ្តាល
- ស្បែកជើងឃ្លុប មានកែង ពណ៌ខ្មៅ កខ្លី ចងខ្សែ។

ក.២- ឯកសណ្ឋានស្ត្រី

- អាវដៃខ្លីក្រណាត់កាគីលាតពណ៌ពងមាន់ កបើក ជើងអាវត្រង់ ផែកចំហៀង ប៉ូលស្មា ហោប៉ៅពីរថ្មេរឧប មានស្ល៉ករកណ្តាល គម្របរាងចំណិតធ្នូបិទដោយឡេវ ខ្ទង់តស្មា លើដៃអាវខាងស្តាំមានសញ្ញាសម្គាល់ក្រសួងបរិស្ថាន និងនៅខាងឆ្វេងមានសញ្ញាសម្គាល់អង្គភាព លើប៉ូលស្មាមានសញ្ញាសក្តិ និងលើហោប៉ៅផ្នែកខាងស្តាំមានបិទផ្លាកឈ្មោះ និងខាងក្រោមផ្លាកឈ្មោះមានពាក់សញ្ញាឡូហ្គោបរិស្ថាន
- សំពត់ខ្លីសម្រុងក្រោមជង្គង់ ក្រណាត់កាគីលាតពណ៌សំបកឪឡឹក ចង្កេះលាតបិទដោយឡេវទម្ពក់មួយនៅចំលើក្បាលរូតផ្នែកខាងក្រោយ ផែកក្រោមផ្នែកខាងក្រោយប្រវែងមួយភាគបីនៃសម្រុងសំពត់ និងមានខ្សែដាក់ខ្សែក្រវ៉ាត់
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រម ទំហំទទឹង៣៨ម.ម.និងបណ្តោយ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងបរិស្ថាននៅចំកណ្តាល
- ស្បែកជើងឃ្លុបមុខឃ្លុបក្រោយ មានកែង ពណ៌ខ្មៅ។

ឯកសណ្ឋានបំពេញការងារតាមបណ្តាអង្គភាពរបស់មន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន មានភ្ជាប់ជាឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

ខ. ឯកសណ្ឋានបំពេញបេសកកម្មសម្រាប់បុរស ស្ត្រី

- អាវដៃវែងក្រណាត់ប៉ាក្រឡាល្អិតចម្រុះពណ៌លំនាំត្រែអ៊ី កត្រង់បិទដោយស្កុតប៉ាន ថ្ទេរឧប ជើងអាវត្រង់ ចុងដៃមានប៉ូលសងខាងដាក់ឡេវ ដៃអាវមានហោប៉ៅស្បោងបញ្ជិតសងខាង មានគម្របសម្រាប់បិទសញ្ញាសម្គាល់ក្រសួងបរិស្ថាននៅខាងស្តាំ និងសញ្ញាសម្គាល់អង្គភាពនៅខាងឆ្វេង ដៃអាវពុះថ្ទេរមានប៉ានកែងដៃជីបភ្លី ខ្នងតស្មាបន្ទះធំ មានសំណាញ់ផ្ទៃខាងក្នុងភ្ជាប់ដោយស្កុតប៉ានចំកណ្តាល ផ្នែកខាងមុខមានហោប៉ៅស្បោងពីររាងបញ្ជិតមានគម្របបិទដោយឡេវនិងស្កុតប៉ាន ខាងស្តាំមានផ្លាកឈ្មោះបិទស្កុត ខាងឆ្វេងមានផ្លាកសញ្ញាទង់ជាតិកម្ពុជា និងមានធីវគ្របឡេវ ហើយលើធីវមានប៉ូលមួយ
- ខោជើងវែងក្រណាត់ប៉ាក្រឡាល្អិតចម្រុះពណ៌លំនាំត្រែអ៊ី ចង្កេះលាតសង់ភ្លីដាក់រូត មានដាក់កៅស៊ូសងខាងរឹបចំហៀងចង្កេះ ប៉ានគូទ ប៉ានជង្គង់ ហោប៉ៅប្រាំបីគឺហោប៉ៅចំហៀងពីរដេរបញ្ជិត ហោប៉ៅក្រោយពីរសងខាងដេរបង្កប់មានគម្របបិទដោយឡេវ ហោប៉ៅស្បោងចំហៀងលើជង្គង់សងខាងមានគម្របជីបភ្លីបញ្ជិតដាក់ឡេវនិងស្កុតប៉ាន ហោប៉ៅស្បោងផ្នែកចំហៀងកំភួនជើងសងខាងមានគម្របបិទដោយស្កុតប៉ាន និងមានដាក់ខ្សែចងរឹបចុងជើងសងខាង
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រម ទំហំទទឹង៣៨ម.ម.និងបណ្តោយ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងបរិស្ថាននៅចំកណ្តាល
- ស្បែកជើងឃ្លុប កវែង ពណ៌កាគី ចងខ្សែ។

ឯកសណ្ឋានបំពេញបេសកកម្មសម្រាប់បុរស ស្ត្រីរបស់មន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានមានភ្ជាប់ជាឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ។

**មាត្រា៥.-**

ឯកសណ្ឋានឧទ្យានុរក្សនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានសម្រាប់បំពេញការងារនៅអង្គភាពនិងបំពេញបេសកកម្មសម្រាប់បុរសស្ត្រី មានដូចខាងក្រោមៈ

- អាវដៃវែងក្រណាត់ប៉ាក្រឡាល្អិតចម្រុះពណ៌លំនាំត្រែអ៊ី កត្រង់បិទដោយស្កុតប៉ាន ថ្ទេរឧប ជើងអាវត្រង់ ចុងដៃមានប៉ូលសងខាងដាក់ឡេវ ដៃអាវមានហោប៉ៅស្បោងបញ្ជិតសងខាង មានគម្របសម្រាប់បិទសញ្ញាសម្គាល់ក្រសួងបរិស្ថាននៅខាងស្តាំ និងសញ្ញាសម្គាល់អង្គភាពនៅខាងឆ្វេង ដៃអាវពុះថ្ទេរមានប៉ានកែងដៃជីបភ្លី ខ្នងតស្មាបន្ទះធំមានសំណាញ់ផ្ទៃខាងក្នុងភ្ជាប់ដោយស្កុតប៉ានចំកណ្តាល ផ្នែកខាងមុខមានហោប៉ៅស្បោងពីរ

រាងបញ្ឆិតមានគម្របបិទដោយខ្សែវនិងស្កុតប៉ាននៅខាងស្តាំមានផ្លាកឈ្មោះបិទស្កុត នៅខាងឆ្វេងមានផ្លាកសញ្ញាទង់ជាតិកម្ពុជានិងមានធីវគ្របខ្សែវ ហើយលើធីវមានប៊ូលមួយ

- ខោជើងវែងក្រណាត់ប៉ាក់ក្រឡាល្អិតចម្រុះពណ៌លំនាំត្រែអ៊ី ចង្កេះលាតសង់ភ្លី ដាក់រូតមានដាក់កៅស៊ូសងខាងចំហៀងចង្កេះ ប៉ានគូទ ប៉ានជង្គង់ ហោប៉ៅប្រាំបីគឺហោប៉ៅចំហៀងពីរដេរបញ្ឆិត ហោប៉ៅក្រោយពីរសងខាងដេរបង្កប់មានគម្របបិទដោយខ្សែវ ហោប៉ៅស្បោងចំហៀងលើជង្គង់សងខាងមានគម្របជីបភ្លីបញ្ឆិតដាក់ខ្សែវនិងស្កុតប៉ាន ហោប៉ៅស្បោងផ្នែកកំភួនជើងសងខាងមានគម្របបិទដោយស្កុតប៉ាន និងចុងជើងដាក់ខ្សែចងសងខាង
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌ប្រាក់ តាមឋានានុក្រម ទំហំទទឹង៣៨ម.ម និងបណ្តោយ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងបរិស្ថាននៅចំកណ្តាល
- ស្បែកជើងឃ្លុប កវែង ពណ៌កាគី ចងខ្សែ។

ឯកសណ្ឋានឧទ្យានុរក្សនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានសម្រាប់បំពេញការងារនៅអង្គភាពនិងបំពេញបេសកកម្មមានភ្ជាប់ជាឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ។

## ផ្នែកទី២
## សញ្ញាសក្តិ

**មាត្រា៦.-**

សញ្ញាសក្តិស្មា មានរាងទ្រវែងស្លួច រាងមុំទាល ប្រវែង១៣០ម.ម. មានទំហំគល់៥៥ម.ម. ទំហំចុង៤៥ម.ម. មានក្រណាត់ផ្ទៃពណ៌បៃតង ភ្ជាប់ដោយខ្សែវមានរូបព្រះសង្ការពណ៌មាសទំហំ១៥ម.ម. ផ្ទៃខាងលើមានរូបក្ងួរស្រូវជារង្វង់ទ្រឡហ្គោ ដែលជាសញ្ញាសម្គាល់ជាផ្លូវការរបស់ក្រសួងបរិស្ថាន និងនៅគែមជុំវិញព័ទ្ធដោយក្បាច់ព្ធរវេញ កំណត់ចំនួនតាមមុខតំណែងរបស់មន្ត្រីរាជការមានដូចខាងក្រោម៖

១- ថ្នាក់អគ្គនាយក៖ សម្គាល់ក្បាច់ខ្សែព្ធរពណ៌មាសចំនួន ៣ខ្សែ ទំហំ ២ម.ម. ព័ទ្ធជុំវិញទ្រនាប់សក្តិមានភ្ជាប់ជាឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

២- ថ្នាក់អគ្គនាយករង៖ សម្គាល់ក្បាច់ខ្សែព្ធរពណ៌មាសចំនួន ៣ខ្សែ ទំហំ ២ម.ម. ព័ទ្ធជុំវិញទ្រនាប់សក្តិ ក្នុងនោះ២ខ្សែក្បាច់ព្ធរពណ៌មាស និង១ខ្សែខាងក្នុងក្បាច់ព្ធរពណ៌មាសមានលក្ខណៈដាច់ៗ មានភ្ជាប់ជាឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

៣- ថ្នាក់ប្រធាននាយកដ្ឋាន៖ សម្គាល់ក្បាច់ខ្សែព្ធរចំនួន ៣ខ្សែ ទំហំ ២ម.ម. ព័ទ្ធជុំវិញទ្រនាប់សក្តិក្នុងនោះ២ខ្សែពណ៌មាស និង១ខ្សែខាងក្នុងក្បាច់ព្ធរពណ៌ប្រាក់មានភ្ជាប់ជាឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ។

៤- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីររាជធានី ខេត្តៈ សម្គាល់ក្បាច់ខ្សែពួរចំនួន៣ខ្សែទំហំ ២ម.ម. ព័ទ្ធជុំវិញទ្រនាប់សក្តិក្នុងនោះ២ខ្សែក្បាច់ពួរពណ៌មាស និង១ខ្សែខាងក្នុងក្បាច់ពួរពណ៌ប្រាក់មានលក្ខណៈដាច់ៗមានភ្ជាប់ជាឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យនេះ។

| ៧ | ឯកឧត្តម | **គង់ ទីប៉ុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៨ | ឯកឧត្តម | **សាន វឌ្ឍនា** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ៩ | ឯកឧត្តម | **ចាន់ សុធី** | អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១០ | ឯកឧត្តម | **ផាន់ ផល្លា** | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១១ | ឯកឧត្តម | **ម៉ី វ៉ាន់** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១២ | លោក | **ម៉ូ ច័ន្ទតីរ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៣ | លោក | **ឆាយ រតនៈ** | ប្រធាននាយកដ្ឋានធានារ៉ាប់រង និង សោធននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៤ | លោក | **គគ្គី សម្បូរណ៍** | ប្រធានការិយាល័យសោធននៃនាយកដ្ឋានធានារ៉ាប់រង និងសោធននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | លេខាធិការ |

**ប្រការ២ .-**

ក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម មានមុខងាររៀបចំ និង ដាក់តែងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម សំដៅជំរុញការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមនៅកម្ពុជា ឱ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព ប្រសិទ្ធភាព ចីរភាព និងស្ថិរភាពហិរញ្ញវត្ថុ និងមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សិក្សា និងរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម ឱ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព ប្រសិទ្ធភាព ចីរភាព និងស្ថេរភាពហិរញ្ញវត្ថុ
- សិក្សាវិភាគគ្រប់ជ្រុងជ្រោយលើស្ថានភាពបច្ចុប្បន្ននៃគោលនយោបាយ និងការអនុវត្តគោលនយោបាយរបបសន្តិសុខសង្គមក្នុងប្រទេសកម្ពុជា ដោយលើកអនុសាសន៍ពីការកំណែទម្រង់រចនាសម្ព័ន្ធក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ រួមទាំងសិក្សា និងរៀបចំក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិចាំបាច់ ដើម្បីជំរុញឱ្យដំណើរការនៃប្រព័ន្ធសន្តិសុខសង្គមទាំងមូលប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ប្រកបដោយតម្លាភាព គណនេយ្យភាព និងចីរភាព
- រៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ប្រព័ន្ធសន្តិសុខសង្គមទាំងមូលរបស់កម្ពុជា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័ត
- សិក្សា និងលើកអនុសាសន៍អំពីការកំណត់អត្រាវិភាគទានសម្រាប់ទ្រទ្រង់ និងការកំណត់តាវកាលិកនៃរបបសន្តិសុខសង្គមនីមួយៗដោយគិតគូរឱ្យបានច្បាស់លាស់អំពីផលប៉ះពាល់នានា ដែលពាក់ព័ន្ធទៅនឹងបន្ទុកថវិការដ្ឋ និងបន្ទុករបស់អ្នកពាក់ព័ន្ធផ្សេងទៀត ដូចជា÷ មន្ត្រីរាជការ នគរបាល ទាហាន និងកម្មករនិយោជិត ព្រមទាំងនិយោជក ផងដែរ
- សិក្សា និងលើកអនុសាសន៍អំពីគោលនយោបាយពន្ធដារដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការនៃរបបសន្តិសុខសង្គមនីមួយៗ សំដៅទ្រទ្រង់ការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គម
- ពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធនានា ទាំងស្ថាប័នរដ្ឋ និងឯកជន ដើម្បីទទួលបានធាតុចូលបន្ថែមសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម ឱ្យមានលក្ខណៈតថភាព និងអាចអនុវត្តបាន
- ពិគ្រោះយោបល់ជាមួយអ្នកជំនាញការ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គមឱ្យស្របតាមស្តង់ដារ និងនិយាមអន្តរជាតិ
- ពិនិត្យឡើងវិញជាប្រចាំលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម ឱ្យស្របតាមនិន្នាការ និងការវិវឌ្ឍជាសកល
- រាយការណ៍ជាប្រចាំជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីវឌ្ឍនភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម ។

**ប្រការ៣ .-**

ក្រុមការងារបច្ចេកទេសសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម មាននាយកដ្ឋានធានារ៉ាប់រង និងសោធន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាលេខាធិការដ្ឋាន ។

**ប្រការ៤ . -**

សមាជិកនៃក្រុមការងារបច្ចេកទេសសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គមត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬអនុប្រធាន (តាមការចាត់តាំងរបស់ប្រធាន) ករណីប្រធានអវត្តមាន ។

**ប្រការ៥ . -**

សេចក្តីសម្រេចលេខ ១៥៣ សសរចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសោធនត្រូវទុកជានិរាករណ៍ ។

**ប្រការ៦ . -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍កសិកម្ម និងជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ......៥៣.....សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១៣អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨ ស្តីពីការបង្កើតក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៨៨៨អនក្រ.បក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ប្រធានក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន

**សម្រេច**

**ប្រការ ១**: ត្រូវបានតែងតាំងសមាសភាពក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- | ឯកឧត្តម **ប្រាក់ សុខុន** | ប្រធាន |
| ២- | ឯកឧត្តម **ស ចាន់ធី** | អនុប្រធាន |
| ៣- | ឯកឧត្តម **ឈី យីសាង** | អនុប្រធាន |

| | |
|---|---|
| ៤- ឯកឧត្តម **ប្រាក់ ផល្លា** | ទីប្រឹក្សា |
| ៥- ឯកឧត្តម **រាល ម៉ារ៉ាវី** | សមាជិក |
| ៦- ឯកឧត្តម **ហេង សូរិន្ទ** | សមាជិក |
| ៧- ឯកឧត្តម **លី សុខហេង** | សមាជិក |
| ៨- ឯកឧត្តម **ទាន សំណាង** | សមាជិក |
| ៩- ឯកឧត្តម **មៅ ទិត្យារុណ** | សមាជិក |
| ១០-ឯកឧត្តម **ហ៊ុន សារឿន** | សមាជិក |
| ១១- ឯកឧត្តម **សាង បូរ៉ាណា** | សមាជិក |
| ១២- ឯកឧត្តម **ដាវ បុត្រមុនី** | សមាជិក |
| ១៣- ឯកឧត្តម **សំលៀង សាលីន** | សមាជិក |
| ១៤- ឯកឧត្តម **ធុច ដាលីន** | សមាជិក |
| ១៥- ឯកឧត្តម **ម៉ែន ទន** | សមាជិក |
| ១៦- កញ្ញា **ព្រាប កែវច័ន្ទមុនី** | សមាជិក |
| ១៧- កញ្ញា **ប៉ែន ច័ន្ទដាវី** | សមាជិក |
| ១៨- កញ្ញា **សាយ សារ៉ាមី** | សមាជិក |
| ១៩- កញ្ញា **មាច សុភាវី** | សមាជិក |
| ២០- លោក **ទូច សុរ៉ាណា** | សមាជិក ។ |

**ប្រការ ២**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៦៦១.......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតអង្គភាពទទួលបន្ទុកគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើតអង្គភាពទទួលបន្ទុកគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងគោលបំណងធ្វើការដឹកនាំ សម្របសម្រួល និង ចូលរួមចំណែកជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការជំរុញកែប្រែ និង ធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ ។

**ប្រការ ២.-**

អង្គភាពនេះ មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ពេជ្រ សម្បត្តិ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ផាន់ ផល្លា** | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ | អនុប្រធាន |
| ៤. ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៥. លោក **ទ៉ាន់ ពុទ្ធិពល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៦. លោក **ម៉ែន សំអោគ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា | សមាជិក |
| ៧. លោក **ម៉ុន បុណ្ណារិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៨. លោក **ជូ វណ្ណៈ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ៩. លោក **អ៊ុំ លុយណា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ១០. លោក **ម៉ី ថាវិន** | លេខាធិការរងក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ១១. លោក **អ៊ឹម សុខធី** | តំណាងក្រុមការងារសម្រាប់កិច្ចប្រជុំ «ច្រកចេញ-ចូលតែមួយ» | សមាជិក |
| ១២. លោក **ម៉ៅ បូរាណា** | តំណាងក្រុមការងារសម្រាប់កិច្ចប្រជុំ «ច្រកចេញ-ចូលតែមួយ» | សមាជិក |
| ១៣. លោក **ពៅ រិទ្ធជ័យសិទ្ធ** | ជំនួយការឯកឧត្តមរដ្ឋលេខាធិការ | លេខាធិការ |

**ប្រការ ៣.-**

អង្គភាពនេះមានតួនាទី និង ភារកិច្ចដូចតទៅ ÷

- ធ្វើជាយន្តការប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការសម្របសម្រួល ពិនិត្យ និង ពិភាក្សាជាមួយក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដើម្បីគោរពជូនរដ្ឋមន្ត្រីពិនិត្យ និង សម្រេច
- ដឹកនាំ និង សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តតាមម៉ាទ្រីសនៃវិធានការ គោលនយោបាយ និង ផែនការសកម្មភាពរបស់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ ក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ផ្តួចផ្តើមគំនិត និង ផ្តល់ធាតុចូលសម្រាប់រៀបចំឯកសារ កម្មវិធី ផែនការសកម្មភាព វិធានការ និង លិខិតបទដ្ឋានពាក់ព័ន្ធនឹងតួនាទីភារកិច្ច ជូនរដ្ឋមន្ត្រីពិនិត្យ និង សម្រេច
- ចូលរួម និង ផ្តល់ធាតុចូលដល់ក្រសួង-ស្ថាប័នក្នុងការពន្លឿន និង អនុវត្តម៉ាទ្រីសស្តីពីវិធានការគន្លឹះ ដើម្បីជំរុញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥
- ធ្វើកិច្ចសហការជាមួយអគ្គនាយកដ្ឋាន អង្គភាពនានា និង ក្រុមការងារផ្សេងៗរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ជួយគាំទ្រដល់ការបំពេញតួនាទីភារកិច្ចរបស់អង្គភាព

- ធ្វើរបាយការណ៍ប្រចាំឆមាសស្តីពីវឌ្ឍនភាពការងារស្តីពីការអនុវត្តតួនាទីភារកិច្ចរបស់អង្គភាព ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បំពេញតួនាទីភារកិច្ចដទៃទៀត តាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៤.-**

ប្រធានអង្គភាពមានតួនាទីជាតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅក្នុងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង កិច្ចប្រជុំនានារបស់ក្រសួង- ស្ថាប័នពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥- ២០២៥ ។

ប្រធានអង្គភាពទទួលខុសត្រូវរួមក្នុងការដឹកនាំអង្គភាព និង កិច្ចប្រជុំរបស់អង្គភាព ព្រមទាំងបំពេញការងារដទៃទៀត តាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ប្រធានអង្គភាពមានសិទ្ធិចាត់តាំងសមាជិកអង្គភាព ចូលរួមជាតំណាងនៅក្នុងកិច្ចប្រជុំនានា ពាក់ព័ន្ធការងាររបស់អង្គភាព ។ តាមការចាត់តាំង ឬ ក្នុងករណីប្រធានអវត្តមាន អនុប្រធានដឹកនាំការងារជំនួស ។

**ប្រការ ៥.-**

សមាជិកអង្គភាពត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានអង្គភាព ក្នុងករណីអវត្តមាន ត្រូវចាត់តំណាងរបស់ខ្លួនចូលរួមជំនួស ។ តំណាងដែលត្រូវបានចាត់ឱ្យចូលរួមជំនួស ត្រូវមានជំនាញច្បាស់លាស់ទាក់ទងនឹងកិច្ចការរបស់អង្គភាព ។

**ប្រការ ៦.-**

ថ្នាក់ដឹកនាំ និង មន្ត្រីពាក់ព័ន្ធក្នុងអគ្គនាយកដ្ឋាន និង អង្គភាពនានារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចូលរួមសហការផ្តល់មតិ និង ឯកសារនានា តាមការស្នើសុំរបស់អង្គភាព សម្រាប់ការបំពេញតួនាទី និង ភារកិច្ចដូចមានក្នុងប្រការ ៣ ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ មិថុនា ឆ្នាំ ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

*កន្លែងទទួល ÷*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម, លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ក្រសួងមុខងារសាធារណៈ*
- *ដូចប្រការ ៧*
  *រាជកិច្ច*
- *ឯកសារ -កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៦២ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
  បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៥៩ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋាន និង អង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

តែងតាំងក្រុមប្រឹក្សាភិបាលវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម **ហ៊ីង សុវណ្ណ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្តម **ហ៊ែល ចំរើន** | អគ្គលេខាធិការ | អនុប្រធាន |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

| | | | |
|---|---|---|---|
| ៤. លោក | **វ៉ៀម សុវណ្ណារ៉ា** | អគ្គលេខាធិការរង | សមាជិក |
| ៥. លោក | **អ៊ិន អេម** | នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៦. លោក | **ម៉ុត សខូរ** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧. លោកស្រី | **ខៀវ ទិមល** | នាយករងវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | លេខាធិការ |

**ប្រការ ២. -**

ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចពិនិត្យ ផ្តល់អនុសាសន៍ និង ដាក់ចេញនូវគំនិតផ្តួចផ្តើមនានាពាក់ព័ន្ធនឹងដំណើរការងារ កម្មវិធីសិក្សា ការបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ និង សកម្មភាពផ្សេងទៀតរបស់វិទ្យាស្ថាន ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សម្រេច ។

**ប្រការ ៣. -**

សមាសភាពក្រុមប្រឹក្សាភិបាល ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។ ក្នុងករណីអវត្តមាន ប្រធានក្រុមប្រឹក្សាភិបាលអាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអនុប្រធានមួយរូប ដើម្បីកោះអញ្ជើញសមាជិកក្រុមប្រឹក្សាភិបាល និង ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល តាមតម្រូវការចាំបាច់របស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៤. -**

ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធ ទីប្រឹក្សា ឬ អ្នកជំនាញការ ក្នុងការចូលរួមផ្តល់យោបល់លើការរៀបចំផែនការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្សសម្រាប់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**ប្រការ ៥. -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦. -**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និង ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

*កន្លែងទទួល ÷*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម, លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ក្រសួងមុខងារសាធារណៈ*
- *ដូចប្រការ ៦*
- *រាជកិច្ច*
- *ឯកសារ - កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៦៣......សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី០៩ខែមិថុនា ឆ្នាំ២០១៥

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការសម្របសម្រួលគម្រោងសាងសង់ស្ពាន និងផ្លូវល្បឿនលឿន ក្រោមទម្រង់វិនិយោគ សាងសង់-ប្រតិបត្តិការ-ផ្ទេរ (BOT) របស់វិទ្យាស្ថានរចនាសិក្សាស្រាវជ្រាវគម្រោងប្លង់គមនាគមន៍ខេត្តហឺណាន សាធារណរដ្ឋប្រជាមានិតចិន

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់

### សម្រេច

**ប្រការ ១:** បង្កើតគណៈកម្មការសម្របសម្រួល និងសិក្សាគម្រោងផ្លូវល្បឿនលឿន និងស្ពាន ក្រោមទម្រង់វិនិយោគ BOT របស់វិទ្យាស្ថានរចនាសិក្សាស្រាវជ្រាវគម្រោងប្លង់គមនាគមន៍ ខេត្តហឺណាន សាធារណរដ្ឋប្រជាមានិតចិន ដែលមានសមាសភាពដូចខាងក្រោម÷

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

| | | | | |
|---|---|---|---|---|
| ១. | លោក | **ម៉ែន ធីរុត្ថ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា (អថ) កសហវ | ប្រធាន |
| ២. | លោក | **ស៊ីង សុគន់** | អគ្គនាយករងផែនការរដ្ឋបាល កសកជ | អនុប្រធាន |
| ៣. | ឯកឧត្តម | **អៀង អូនលី** | អភិបាលរងរាជធានីភ្នំពេញ សាលារាជធានីភ្នំពេញ | សមាជិក |
| ៤. | លោក | **ប៊ុន បុណ្ណារិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កសហវ | សមាជិក |
| ៥. | លោក | **ង៉ាវ សុផល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កសហវ | សមាជិក |
| ៦. | លោក | **ស៊ិន បូណរិមី** | នាយកទីចាត់ការរៀបចំក្រុង សាលារាជធានីភ្នំពេញ | សមាជិក |
| ៧. | លោក | **រស់ បរម** | ប្រធាននាយកដ្ឋានវិនិយោគ (នវ) នៃអថ កសហវ | សមាជិក |
| ៨. | លោក | **ឈួន សំរិទ្ធិ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល នៃអថ កសហវ | សមាជិក |
| ៩. | លោក | **យុន ហេង** | ប្រធាននាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត នៃគណៈកម្មការវិនិយោគកម្ពុជា កអក | សមាជិក |
| ១០. | លោក | **មឿង វិសុទ្ធ** | ប្រធាននាយកដ្ឋានស្តីទីនាយកដ្ឋានត្រួតពិនិត្យ និងតាមដានគម្រោងវិនិយោគ កអក | សមាជិក |
| ១១. | លោក | **យ៉េន សុតំណា** | អនុប្រធាននាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃអគ្គលេខាធិការដ្ឋាន កសហវ | សមាជិក |
| ១២. | លោក | **ឃុន សុខា** | អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស កសកជ | សមាជិក |
| ១៣. | លោក | **ហ៊ូ គុណាវុឌ្ឍន៍** | អនុប្រធាននាយកដ្ឋានវិនិយោគ នៃអថ កសហវ | សហជិក |
| ១៤. | លោក | **ដារី ចេតនា** | អនុប្រធាននាយកដ្ឋានវិនិយោគ នៃអថ កសហវ | សមាជិក |
| ១៥. | លោក | **ហេង ណារិទ្ធ** | អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ កសហវ | សមាជិក |
| ១៦. | លោក | **ម៉ាង សុតាវ៉ា** | ប្រធានការិយាល័យគ្រប់គ្រងបំណុល រដ្ឋបាល និងសរុប នាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល នៃអថ កសហវ | សមាជិក |
| ១៧. | លោក | **ខិម ម៉ាក់ធារិទ្ធ** | ប្រធានការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន នវ នៃអថ កសហវ | សមាជិក |
| ១៨. | លោក | **ញាន វណ្ណៈ** | ប្រធានការិយាល័យដោះស្រាយផលប៉ះពាល់ទី១ នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ នៃអគ្គលេខាធិការដ្ឋាន កសហវ | សមាជិក |
| ១៩. | លោក | **នង គុន្ធាវ៉ា** | ប្រធានការិយាល័យមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ កសកជ | សមាជិក |

| | | | |
|---|---|---|---|
| ២០. លោក | **ហេង ជំនិត** | អនុប្រធានការិយាល័យសវនកម្មទី៤ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ កសហវ | សមាជិក |
| ២១. លោក | **ស ម៉ិនអ៊ាង** | អនុប្រធានការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន នវ នៃអថ កសហវ | សមាជិក |
| ២២. លោក | **លុយ សុក្រិត** | អនុប្រធានការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន នវ នៃអថ កសហវ | លេខា |

**ប្រការ ២:** គណៈកម្មការនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ពិនិត្យ និងផ្តល់យោបល់ អំពីនីតិវិធី ក្របខ័ណ្ឌគតិយុត្ត បទដ្ឋានបច្ចេកទេស ព្រមទាំងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃគម្រោង
- សិក្សា និងផ្តល់យោបល់ អំពីហានិភ័យពាក់ព័ន្ធនានា នៃគម្រោង រួមទាំងផលប៉ះពាល់ខាងបរិស្ថាន និងសង្គម
- រៀបចំរបាយការណ៍ ស្តីពីលទ្ធផលការងារ។

**ប្រការ ៣:** ប្រធានគណៈកម្មការ អាចអញ្ជើញសមាជិកចូលរួមប្រជុំ តាមការចាំបាច់។

**ប្រការ ៤:** អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន សាលារាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ...ឧស....

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ... ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន អេផិច អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អេផិច អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី (APEX INTERNATIONAL (CAMBODIA) LTD) តំណាងដោយ លោក PANG ALAN KWAN KWOK បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ អេផិច អ៊ិនឌើណេសិនណល (ខេមបូឌា) អិលធីឌី"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការ ជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹង វិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : [illegible] ឧស.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តី ពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន បាយ័ន ហ្គាមេន ហ្វាកធើរី ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន បាយ័ន ហ្គាមេន ហ្វាកធើរី (BAYON GARMENT FACTORY CO., LTD.) តំណាងដោយ លោក KINGHORN JOHN CAMERON បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ បាយ៉ែន ហ្គាមេន ហ្វាកធើរី ខូអិលធីឌី "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤**: ប្រកាសលេខ ២៣០ឧរថ.កឧ.ប្រក. ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន បាយ័ន ហ្គាមេន ហ្វាកធើរី ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៧៤...ឧស.ភស.ក្រសក-០៤

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តី ពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ខេមបូ ហែនសាំ អិលធីឌី ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥។

## ស ម្រេ ច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូ ហែនសាំ អិលធីឌី (CAMBO HANDSOME LTD.) តំណាងដោយ លោក LEE SINJAE បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិអង្គតែរ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ (អតីតឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល)។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រកាត់ដេរសម្លៀកបំពាក់ ខេមបូ ហ៊ែនសាំ អិលធីឌី "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤**: ប្រកាសលេខ ៦៨៥ ឧរថ.កឧ.ប្រក. ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ